## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃ សុក្រ ៨ កើត ខែស្រាពណ៍ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦*

*រាជធានីភ្នំពេញ ថ្ងៃទី៥ ខែសីហា ឆ្នាំ ២០២២*

# សេចក្ដីជូនដំណឹងស្ដីពី

# ការប្រារព្ធទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោក និងពិធីដាក់ឱ្យប្រើប្រាស់ជាផ្លូវនូវរបាយការណ៍អំពីអំពើហិង្សាផ្អែកលើយេនឌ័រលើស្ត្រីជនជាតិដើមភាគតិចនៅខេត្តចំនួន ៣ នៅកម្ពុជា

ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០២២ វេលាម៉ោង៨៖៣០ ព្រឹក ដល់ម៉ោង ៥៖០០ ល្ងាច ខាងមុខនេះ នៅសណ្ឋាគារសាន់វេ ភ្នំពេញ **សម្ព័ន្ធជនជាតិដើមភាគតិច** នឹងរៀបចំទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកលើកទី ២៨ និងលើកទី ១៨ នៅកម្ពុជា ក្រោមប្រធានបទ ***តួនាទីស្ត្រីជនជាតិដើមភាគតិចក្នុងការអភិរក្ស និងការផ្ទេរចំណេះដឹងប្រពៃណី*** និងពិធីដាក់ឱ្យប្រើប្រាស់ជាផ្លូវការរបាយការណ៍ស្តីពី ***អំពើហិង្សាផ្អែកលើយេនឌ័រលើស្ត្រីជនជាតិដើមភាគតិច នៅក្នុងខេត្តចំនួន៣នៅកម្ពុជា***។ ពិធីនេះនឹងមានការចូលរួមពីស្ថាប័នអង្គការ ស្ថានទូត និងសហគមន៍ជនជាតិដើម ភាគតិចមកពី បណ្ដាខេត្តផ្សេងៗនៅក្នុងប្រទេសកម្ពុជា។

កម្មវិធីនេះធ្វើឡើងក្នុងគោលបំនងដើម្បីផ្សព្វផ្សាយពីតួនាទីដ៏សំខាន់របស់ស្ត្រីជនជាតិដើមភាគតិចក្នុងការអភិរក្ស និងផ្ទេរចំណេះដឹងប្រពៃណី ដើម្បីធ្វើឱ្យប្រសើរឡើងនៃការរស់នៅក្នុងគ្រួសារ សហគមន៍ និងសង្គមជាតិ ហើយក្នុងនោះដែរ យើងក៏រៀបចំសម្ពោធដាក់ឱ្យប្រើប្រជាផ្លូវការនូវរបាយការណ៍ស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រមកលើស្ត្រីជនជាតិដើមភាគតិចនៅក្នុងខេត្តចំនួន៣ ដូចជា ខេត្តស្ទឹងត្រែង មណ្ឌលគិរី និងរតនគិរី។

ក្នុងនោះដែរកម្មវិធីនឹងមានកម្សាន្តផ្សេងៗដូចជាការសម្តែងសិល្បៈប្រពៃណី របាំ រឿងអប់រំខ្លី ចម្រៀង និងការតាំងពិព័រណ៍សម្ភារៈ និងម្ហូបអាហារតាមជនជាតិដើមនីមួយៗផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងសារព័ត៌មានទាំងអស់ជ្រាបជាព័ត៌មាន។